


## ការរស់នៅដោយមានមេរោគ HIV និងជំងឺអេដស៍

ការរស់នៅដោយមានមេរោគHIVនិងជំងឺអេដស៍ឬ ដោយដឹងថាអ្នកជាទីស្រឡាញ់ណាម្នាក់របស់លោកអ្នកមានមេរោគHIVនិងជំងឺអេដស៍ នោះវាអាចជាពេលវេលាដ៏លំបាកសំរាប់លោកអ្នក។ នេះគឺជាការពិតប្រសិនបើលោកអ្នកមានដើមកំណើតមកពីប្រទេសដែលមានវប្បធម៌និងភាសាផ្សេងៗនោះ។ ការចែករំលែកក្តីព្រួយបារម្ភនិងការលំបាករបស់លោកអ្នកជាមួយអ្នកណាម្នាក់នោះអាចជួយសំរួលការលំបាក និងបន្ថយការភាន់ច្រឡំបានខ្លះ។

### តើលោកអ្នកត្រូវការជំនួយឬបុគ្គលិកគាំទ្រ:

- ដើម្បីជួយលោកអ្នកឱ្យយល់ព័តមានអំពីសុខភាពលោកអ្នកឬសុខភាពអ្នកដែលលោកអ្នកមើលថែទាំ?
- ដើម្បីនិយាយប្រាប់ពិស្ថានភាពនិងក្តីបារម្ភរបស់លោកអ្នក?
- ដើម្បីជួយសមាជិកគ្រួសារលោកអ្នកឱ្យយល់ពីស្ថានភាពលោកអ្នក?
- ដើម្បីជួយវេជ្ជបណ្ឌិតលោកអ្នកនិងសង្គមការីឱ្យយល់ពីសេចក្តីត្រូវការរបស់លោកអ្នក?
- ជួយជូនអ្នកទៅតាមការណាត់ជួបរបស់លោកអ្នក?

កិច្ចបំរើពហុវប្បធម៌ផ្នែកមេរោគHIV/ជំងឺអេដស៍និងជំងឺរលាកថ្លើមប្រភេទ**គ** (MHAHS) អាចផ្តល់ការគាំទ្រដែលលោកអ្នកត្រូវការ។ យើងមានបុគ្គលិកគាំទ្រភេទប្រុសនិងស្រីដែលគេហៅថាបុគ្គលិកគាំទ្រ(co-workers)ដែលមានដើមកំណើតពីប្រទេសអាស៊ី អាហ្វ្រិក អឺរ៉ុប អាមេរិកកណ្តាលនិងអាមេរិកខាងត្បូង។ គេទាំងនោះយល់ដឹងពីជីវិតរស់នៅដែលមានមេរោគHIV/ជំងឺអេដស៍និងការប្រឈមមុខនឹងបញ្ហាវប្បធម៌ផ្សេងៗ។ បុគ្គលិកគាំទ្រទាំងនោះអាចផ្តល់នូវការគាំទ្រជាបន្តបន្ទាប់ផ្នែកផ្លូវចិត្តនិងការជូនទៅរកសេវា(កិច្ចបំរើ)ដែលមានសារៈប្រយោជន៍ដល់លោកអ្នកផ្សេងៗទៀត។ លោកអ្នកអាចជួបជាមួយបុគ្គលិកគាំទ្រទៅតាមពេលវេលាដែលអាចជួបគ្នាបាន។

### តើអ្នកណានឹងដឹងអំពីស្ថានភាពរបស់ខ្ញុំ?

អ្នកប្រហែលជាមានការព្រួយបារម្ភក្នុងការស្វរកបុគ្គលិកគាំទ្រដោយហេតុថាបុគ្គលិកគាំទ្រនោះមកពីសហគមន៍លោកអ្នកឬមានវប្បធម៌ដូចលោកអ្នកដែរ ហើយបារម្ភថាអ្នកនោះនឹងដឹងពីស្ថានភាពរបស់លោកអ្នក។

កិច្ចបំរើពហុវប្បធម៌ផ្នែកមេរោគHIVជំងឺអេដស៍និងជំងឺរលាកថ្លើមប្រភេទគមានវិធានការដូចខាងក្រោមនេះដើម្បីរក្សារឿងផ្ទាល់ខ្លួនរបស់លោកអ្នក:

- លោកអ្នកមិនចាំបាច់ប្រាប់ឈ្មោះពិតរបស់លោកអ្នកទេ
- បុគ្គលិកគាំទ្រយើងយល់ដឹងពីសារៈសំខាន់នៃការពិភាក្សាជាមួយអ្នកហើយមិននិយាយប្រាប់អ្នកដ៏ទៃទេបើគ្មានការអនុញ្ញាតិពីលោកអ្នក
- បុគ្គលិកគាំទ្រយើងមានច្បាប់និងមានការពិន័យយ៉ាងតឹងរឹងដូចគ្នានឹងបុគ្គលិកសុខាភិបាលផ្សេងៗទៀតនៅក្នុងប្រទេសអូស្ត្រាលីដែរ
- យើងនឹងមិននិយាយពីរឿងនិងស្ថានភាពរបស់លោកអ្នកប្រាប់ទៅកន្លែងធ្វើការផ្សេងៗដោយគ្មានការអនុញ្ញាតិពីលោកអ្នកទេ

- បុគ្គលិកគាំទ្រយើងធ្វើការច្រើនកន្លែង ម្លោះហើយនៅក្នុងសហគន៍គេមិនដឹងថាបុគ្គលិកទាំងនោះធ្វើការតែនៅកិច្ចបំរើផ្នែកមេរោគHIV/ជំងឺអេដស៍ទេ ដូច្នេះហើយបុគ្គលិកគាំទ្រយើងអាចជួយរក្សារឿងសំងាត់ផ្ទាល់ខ្លួនលោកអ្នកបាន។

មនុស្សនៅក្នុងសហគមន៍ខ្លះបានយល់ច្រឡំចំពោះជនដែលរស់នៅដោយមានមេរោគHIV/ជំងឺអេដស៍។ បុគ្គលិកគាំទ្រយើងយល់យ៉ាងច្បាស់អំពីរឿងនេះពីព្រោះបុគ្គលិកទាំងនេះត្រូវបានគេជ្រើសរើសយ៉ាងសរិតសំរាំងនិងបានទទួលការហ្វឹកហ្វឺនពីរឿងនេះទៀតផង។ចូរចងចាំថា ប្រសិនបើលោកអ្នកនៅតែបារម្ភពីរឿងផ្ទាល់ខ្លួននេះលោកអ្នកអាចរកបុគ្គលិកគាំទ្រដែលមានដើមកំណើតនិងវប្បធ៌មផ្សេងទៀតបាន។

## សិទ្ធិរបស់លោកអ្នក

ដោយលោកអ្នកជាអតិថិជននៃកិច្ចបំរើរបស់យើងលោកអ្នកមានសិទ្ធិនិងទទួលបាននូវសេចក្តីគោរព និងការរក្សាភាពសំងាត់ផ្ទាល់ខ្លួនរបស់អ្នក។ ប្រសិនបើលោកអ្នកដឹងថា លោកអ្នកពុំត្រូវបានគេផ្តល់កិច្ចបំរើឱ្យបានសមរម្យពីសំណាក់បុគ្គលិកនៃកិច្ចបំរើពហុវប្បធ៌មផ្នែកមេរោគ HIV/ជំងឺអេដស៍និងជំងឺរលាកថ្លើមប្រភេទគទេនោះ លោកអ្នកអាចដាក់ពាក្យប្តឹងបាន។ លោកអ្នកអាចទាក់ទងប្រធាននៃកិច្ចបំរើនេះតាមទូរស័ព្ទឬដោយសរសេរសំបុត្រក៏បាន។

## តើកិច្ចបំរើនេះយកលុយដែរឬទេ?

កិច្ចបំរើនេះមិនគិតលុយទេ។ យើងក៏មិនត្រូវការកាតមីឌីឃែនិងប័ណ្ណសំគាល់ខ្លួនផ្សេងៗទៀតដែរ។

## តើខ្ញុំអាចទាក់ទងតាមរបៀបណាដែរ?

លោកអ្នកអាចទាក់ទងមកកិច្ចបំរើយើងឬសាកសួរវេជ្ជបណ្ឌិតឬសង្គមការី(អ្នកធ្វើការផ្នែកសង្គម)ឱ្យគេជួយទាក់ទាក់ទងមកយើងបានតាមទូរស័ព្ទលេខ (02) 9515 1234 នៅក្នុងពេលម៉ោងធ្វើការ។ បុគ្គលិកគាំទ្រយើងពុំធ្វើការនៅក្នុងការិយាល័យពេញពេលទេ ប៉ុន្តែយើងអាចចាត់ចែងឱ្យអ្នកជួបបុគ្គលិកគាំទ្របាន។ ប្រសិនបើលោកអ្នកត្រូវការនិយាយជាមួយយើងខ្ញុំជាភាសាខ្មែរ សូមលោកអ្នកទូរស័ព្ទទៅកិច្ចបំរើផ្នែកបកប្រែភាសា (Translating and Interpreting Service (TIS) តាមលេខ 131 450 ដោយត្រូវបង់ថ្លៃដូចទូរស័ព្ទក្នុងតំបន់ (local call) ដែរ។ នៅពេលដែលអ្នកបកប្រែឆ្លើយទូរស័ព្ទ លោកអ្នកត្រូវប្រាប់គេឱ្យទូរស័ព្ទមកលេខទូរស័ព្ទរបស់យើង។ បន្ទាប់មកលោកអ្នកនឹងអាចនិយាយជាមួយយើងជាភាសាខ្មែរតាមរយៈអ្នកបកប្រែ។

កូនសៀវភៅព័តមាននេះមានជាភាសាអង់គ្លេសនិងភាសាសហគមន៍ផ្សេងៗទៀតមាននៅក្នុងគេហទំព័រយើង www.mhahs.org.au
។

## កន្លែងទាក់ទងសំខាន់ផ្សេងៗទៀត

ចូលទូរស័ព្ទទៅលេខ **131 450** ប្រសិនបើលោកអ្នកចង់ប្រើកិច្ចបំរើផ្នែកបកប្រែភាសាខ្មែរនៅពេលទូរស័ព្ទមកកិច្ចបំរើណាមួយខាងក្រោមនេះ។

ពត៌មានស្តីអំពីមេរោគ HIV (02) 9332 9700 ឬ 1800 451 600
ACON: (02) 9206 2000
មណ្ឌលសុខភាពផ្លូវភេទស៊ីដនី (02) 9382 7440